# *dreams* in the KNOT

**WHEN :** August 8, 2009
**WHERE :** Restaurant 112
**THEME :** Basketful Of Love







# The Wedding Planners

*WORDS & PHOTOS* Mangorain

The Wedding Planners is the brainchild of two well-established wedding planners from Malaysia who decided to merge their efforts to cater to a new market in Cambodia. Having over 15 years of experience in the wedding industry between them, they are excited and passionate about bringing fresh creative ideas infused with Khmer traditions to couples in Cambodia who are intending to tie the knot.

Wedding planning is an entirely new concept here in Cambodia. Whilst weddings are very popular in Cambodia, averaging about 50 – 60 weddings per day during the wedding season, wedding planners are almost unheard of. However, these bright and creative entrepreneurs are positive that wedding planners for hire will become popular in years to come.

"We are really not expecting the market to embrace us with open arms for now. We just want to let them know that we're here, we're an option," says Eileen Lui, co-owner of TWP who have been based in Cambodia for awhile now. "The idea is for them to be able to come to terms slowly with the fact that there are more creative ways to plan a wedding, yet still keeping it close to tradition and culture," she adds.

Aside from the creativity and styles which make each wedding unique, hiring a wedding planner helps you keep to deadlines and budgets as well as eliminates the headaches and stress of having to deal with ten different parties when you only need to deal with one. "A lot of couples plan their own wedding with the help of their families. What happens is that they could possibly have different views, or perhaps they do not know the best places to source an item, but definitely, the biggest issue is that the couple and sometimes the family do not get to enjoy

សេវាកម្មអ្នករៀបចំអាពាហ៍ពិពាហ៍ជាគំនិតច្នៃប្រឌិតរបស់អ្នករៀបចំអាពាហ៍ពិពាហ៍ដ៏ល្បីល្បាញពីររូបមកពីប្រទេសម៉ាឡេស៊ីដែលបានសម្រេចចិត្តចូលរួមសហការក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីផ្គត់ផ្គង់ទីផ្សារដែលនៅថ្មីនៅឡើយនៅកម្ពុជា ។ ជាមួយបទពិសោធន៍ចំនួន ១៥ ឆ្នាំ ផ្នែកឧស្សាហកម្មអាពាហ៍ពិពាហ៍ ពួកគេមានឆន្ទៈមោះមុត និងទឹកចិត្តស្រឡាញ់ខ្លាំងក្លា ក្នុងការនាំយកមកនូវគំនិតច្នៃប្រឌិតល្អៗ បញ្ចូលជាមួយប្រពៃណីខ្មែរសម្រាប់គូស្នេហ៍នៅកម្ពុជាដែលមានគម្រោងនឹងរៀបការ ។

សេវាកម្មរៀបចំពិធីអាពាហ៍ពិពាហ៍ជាការច្នៃប្រឌិតមួយថ្មីសុទ្ធសាធនៅកម្ពុជា ។ នៅកម្ពុជា នារដូវនិយមរៀបអាពាហ៍ពិពាហ៍បំផុត ជាមធ្យមក្នុងមួយថ្ងៃពិធីមង្គលការប្រហែល ៥០ ទៅ ៦០ កន្លែង ត្រូវបានរៀបចំឡើង ដែលសេវាកម្មអ្នករៀបចំអាពាហ៍ពិពាហ៍ស្ទើរតែមិនធ្លាប់បានដឹង ។ ទោះយ៉ាងណាក៏ដោយ អ្នកវិនិយោគប្រកបដោយគំនិតច្នៃប្រឌិត និងវៃឆ្លាតរូបនេះមានគំនិតសុទិដ្ឋិនិយមថា សេវាកម្មអ្នករៀបចំអាពាហ៍ពិពាហ៍ប្រាកដជាទទួលបានការពេញនិយមនាអនាគតដ៏ខ្លីខាងមុខនេះ ។






the wedding whole-heartedly because they are running around making sure everything is going well," comments Leticia Hsu, co-owner of TWP. "Over the years, a lot of couples in Malaysia have sought out wedding planners simply because they want themselves and their families to be able to fully enjoy their wedding," she continues.

TWP officially started their operations in Cambodia on the 15th June 2009 and brought with them a network of international wedding vendors from Malaysia, Singapore, Indonesia, Hong Kong and also Australia and New Zealand.

TWP also provides party planning for private functions and celebrations.

អ្នកនាង Eileen Lui ជាសហនាយកនៃក្រុមហ៊ុន TWP ដែលមានវត្តមាននៅប្រទេសកម្ពុជាអស់មួយរយៈពេលកន្លងមកនេះ បានមានប្រសាសន៍ថា "យើងពិតជាមិនរំពឹងទុកថាទីផ្សារនឹងខិតចូលមកជិតយើងជាមួយនឹងការលាដៃស្វាគមន៍ក្នុងពេលឥឡូវនេះទេ។ យើងគ្រាន់តែចង់ឱ្យពួកគេដឹងថា យើងមានវត្តមាននៅទីនេះ យើងជាជម្រើសមួយរបស់ពួកគេ។" អ្នកនាងបានបន្ថែមទៀតថា "ពួកគេចាប់ផ្តើមយល់បណ្តើរៗថា មានមធ្យោបាយថ្មីប្រកបដោយភាពច្នៃប្រឌិតប្លែកៗ ក្នុងការរៀបចំអាពាហ៍ពិពាហ៍ ប៉ុន្តែនៅតែទាក់ទងជិតស្និទ្ធជានិច្ចជាមួយប្រពៃណី និងវប្បធម៌។"

ក្រៅពីគំនិតច្នៃប្រឌិត និងស្ទីលទាន់សម័យ ដែលធ្វើឱ្យពិធីអាពាហ៍ពិពាហ៍នីមួយៗមានលក្ខណៈពិសេសលេចធ្លោ ការជួលអ្នករៀបចំពិធីអាពាហ៍ពិពាហ៍ពិតជាអាចជួយឱ្យអ្នកធ្វើអ្វីៗទាន់ពេលកំណត់ និងចំណេញថវិកា ក៏ដូចជាកាត់បន្ថយភាពស្មុគស្មាញ តានតឹងចិត្តក្នុងការទំនាក់ទំនងជាមួយនឹងភាគីច្រើនផ្សេងៗគ្នា ខណៈពេលដែលអ្នកអាចជ្រើសយកការទំនាក់ទំនងមកភាគីតែមួយប៉ុណ្ណោះក៏បាន។

អ្នកនាង Leticia Hsu ជាសហនាយកនៃក្រុមហ៊ុន TWP ក៏បានបញ្ចេញយោបល់ថា "គូស្នេហ៍ជាច្រើនមានគម្រោងនឹងរៀបចំពិធីមង្គលការរបស់ពួកគេដោយមានការជួយជ្រោមជ្រែងពីក្រុមគ្រួសាររបស់ពួកគេ។ អ្វីដែលកើតឡើងនោះគឺថា ពួកគេប្រហែលជាមានទស្សនៈខុសគ្នា ឬប្រហែលជាពួកគេមិនស្គាល់ប្រភពល្អបំផុតក្នុងការស្វែងរករបស់របរ ប៉ុន្តែជាការពិត បញ្ហាធំបំផុតគឺថា គូស្នេហ៍ និងពេលខ្លះអាចជាក្រុមគ្រួសារមិនបានសប្បាយរីករាយដោយអស់ពីចិត្តពិតប្រាកដឡើយ ព្រោះពួកគេត្រូវរវត់ទៅរវត់មកដើម្បីឱ្យប្រាកដក្នុងចិត្តថាពិធីដំណើរការទៅបានល្អ"។ អ្នកនាងបានបន្ថែមទៀតថា "ជាច្រើនឆ្នាំកន្លងមកនេះ គូស្នេហ៍ជាច្រើននៅម៉ាឡេស៊ីបានស្វែងរកសេវាកម្មអ្នករៀបចំអាពាហ៍ពិពាហ៍បានយ៉ាងងាយស្រួល ពីព្រោះពួកគេចង់ឱ្យខ្លួនពួកគេផ្ទាល់ ព្រមទាំងក្រុមគ្រួសារអាចសប្បាយរីករាយក្នុងពិធីអាពាហ៍ពិពាហ៍បានយ៉ាងពេញលេញពិតប្រាកដ។"

ក្រុមហ៊ុន TWP បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនជាផ្លូវការនៅប្រទេសកម្ពុជាកាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ដោយនាំយកមកនូវបណ្តាញអ្នករៀបចំពិធីអាពាហ៍ពិពាហ៍ស្តង់ដារអន្តរជាតិមកពីប្រទេសម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី ហុងកុង អូស្ត្រាលី និងញូវហ្សេឡែន។ ក្រុមហ៊ុន TWP ក៏ផ្តល់ជូនផងដែរនូវសេវាកម្មរៀបចំពិធីជប់លៀងសម្រាប់ពិធីជាលក្ខណៈឯកជន និងពិធីអបអរសាទរផ្សេងៗ។



LOVELY!

Eileen Lui had her own wedding last September in Kayumanis, Nusa Dua, Indonesia. Congrats from F Magazine!